# ការវិភាគ

## របស់ព្រះតេជព្រះគុណបណ្ឌិត ហុក-សាវណ្ណ
## ក្រោមប្រធានបទ វាសនានៃអ្នកដឹកនាំវត្តទូលព្រះរាជា

website ៖ www.hoksavann.org

ថ្ងៃទី២ ឧសភា ២០០៩



លើកមុនយើងបានវិភាគម្តងរួចហើយ អំពីសកម្ម-ភាពរបស់លោកធាន-វុឌ្ឍី នៅវត្តទូលព្រះរាជា ឃុំពោបាន ស្រុកកោះធំ ខេត្តកណ្តាល ប្រទេសកម្ពុជា ។ ដំបូងលោកធាន-វុឌ្ឍីតាំងខ្លួនជាសម្តេចជួន-ណាត ដឹងជាតិក្រោយពេលដែលទាញមនុស្សឲ្យជឿលែងបានទៀតហើយ ក៏តាំងខ្លួនជាព្រះសិអារ្យមេត្រីយ៍ ហើយក្នុងពេលថ្មីៗនេះ បានតាំងខ្លួនជាព្រះពុទ្ធអង្គតែម្តង ដោយហៅខ្លួនឯងថា «តថាគត» ក្នុងខ្សែអាត់ថតសម្លេងនិងតាមវីដេអូ ។

ក្រោយពេលដែលមន្ត្រីសង្ឃទៅគំរាមមិនឲ្យធ្វើអ្វីខុសពីធម៌វិន័យរបស់ព្រះពុទ្ធសាសនា មានមិនឲ្យបំបួសព្រះសង្ឃជាដើម លោកធាន-វុឌ្ឍីជាគ្រហស្ថមិនហ៊ានបំបួសព្រះសង្ឃទៀតឡើយ ។ តាមរយៈវីដេអូ គេឃើញលោកធាន-វុឌ្ឍីបំបួសព្រះសង្ឃឲ្យស្លៀកសពាក់ស ។ ដូច្នេះចាប់ពីពេលនេះទៅ ទំនងជាឈប់ឲ្យគេធ្វើកឋិនទៀតហើយ ។ ការធ្វើកឋិនពីមុនក្តី ទោះបីពេលនេះធ្វើក្តី មិនឡើងជាកឋិនឡើយ មិនបានបុណ្យកឋិនឡើយ ព្រោះមិនត្រឹមត្រូវតាមពុទ្ធានុញ្ញាត ។

គួរអនិច្ចាមួយទៀត លោកធាន-វុឌ្ឍីបានពោលតិះដៀលព្រះសង្ឃខ្មែរទាំងមូល ជាពិសេសមន្ត្រីសង្ឃ ថាគ្មានតម្លៃអ្វីទេ គេថ្វាយបង្គំដោយសារយកស្បង់ចីពរព្រះមកពាក់ ចំណែកខ្លួនគាត់វិញជាអ្នកមានបុណ្យ ។ ការពោលដៀលព្រះសង្ឃដែលបួសត្រឹមត្រូវតាមធម៌វិន័យ មានទោសធ្ងន់តាមផ្លូវព្រះពុទ្ធសាសនា ។ ការកាន់ព្រះពុទ្ធសាសនា គឺប្រតិបត្តិតាមធម៌វិន័យពាក្យប្រៀនប្រដៅរបស់ព្រះ

ពុទ្ធអង្គណាមួយ ដូចពុទ្ធសាសនិកជនខ្មែរគោរពតាមព្រះពុទ្ធដីកានៃព្រះសាមណគោតម ដែលមានគម្ពីរព្រះត្រៃបិដកជាគោល ចំណែកលោកធាន-វុឌ្ឍីសំអាងអ្វីថាខ្លួនជាអ្នកមានបុណ្យ រហូតតាំងខ្លួនជាព្រះពុទ្ធទៀត ។ តាមការសង្កេតមើលនូវរូបភាពមួយសន្លឹក ឃើញរូបលោកធាន-វុឌ្ឍីអង្គុយលើផ្កាឈូកអណ្ដែតលើពពក ហើយនៅខាងក្រោមមានរូបភាពនាងគង់-ស៊ីអ៊ីមឈរជាពីរជួរអមជាសាវក ។ នេះបញ្ជាក់ថា អ្នកជំនួយការមានបច្ចេកទេសខាងកំព្យូទ័រ ដកស្រង់រឿងគង់-ស៊ីអ៊ីម ដែលគេប្រឌិតនៅហុងកុង មកលើកតំកើងលោកធាន-វុឌ្ឍី ជាព្រះសមណគោតម ហើយព្រះម៉ែគង់-ស៊ីអ៊ីមជាសាវក ។

យើងជាអ្នកសិក្សាតាមគម្ពីរព្រះត្រៃបិដកអដ្ឋកថាដីកា លុះមកស្ដាប់លោកធាន-វុឌ្ឍីនិយាយ មិនដឹងថាគាត់ចង់និយាយថាម៉េច ព្រោះមិនចូលក្នុងគម្ពីរព្រះពុទ្ធសាសនាសោះ ព្រោះគាត់ទើបអាយុបានជាង៣០ឆ្នាំ សិក្សាផ្លូវលោកនិងផ្លូវធម៌បានតិច ម្ល៉ោះហើយនិយាយព្រះពុទ្ធសាសនាមិនត្រូវ ក្លាយជាមនុស្សរវើរវាយនិយាយគ្មានការពិត ដូចជានិយាយថា ព្រះបង្កើតទឹកដីភ្លើងខ្យល់ និងបង្កើតកូនបាន១៨សែនកោដិ ។ តើព្រះណាបង្កើតវត្ថុទាំងនោះ ហើយព្រះពុទ្ធបានលះបង់កាមកិលេសអស់ហើយ ហេតុអ្វីបានជាព្រះពុទ្ធបង្កើតកូនរហូតដល់ទៅ១៨សែនកោដិ ? គាត់ពោលថា គាត់ហោះទៅស្ថានព្រះព្រហ្ម ឈ្មោះវិរសណាព្រហ្ម គឺគាត់ទៅដោយឫទ្ធិ អ្នកគ្មានឫទ្ធិទៅពុំបានឡើយ ទំនងជាជិះទូកថត ព្រោះពុច្រវាចែវ ហើយបច្ចេកទេសកុំព្យូទ័រធ្វើដូចជាហោះ ដូចភាពយន្តដែលគេធ្លាប់ធ្វើក្នុងរឿងផ្សេងៗ ។ គាត់ដើរតាមជ្រលងភ្នំជាមួយសហការីពីរបីនាក់ មកដល់កន្លែងមួយគាត់ពោលថា កន្លែងនេះព្រះពុទ្ធយាងមកសំដែងធម៌ ហើយកន្លែងនោះព្រះឥន្ទធ្លាប់មកប្រជុំគ្នា ។ តាមប្រវត្តិព្រះពុទ្ធសាសនា គ្មានឃើញព្រះពុទ្ធមកសំដែងធម៌នៅប្រទេសកម្ពុជាឡើយ ។

ការនិយាយរវើរវាយជារឿងផ្ទាល់ខ្លួនរបស់គាត់ ប៉ុន្តែបញ្ហាមួយដែលប៉ះពាល់ដល់ផលប្រយោជន៍សាធារណជនខ្មែរ គឺការឃោសនាលក់របស់របរផ្សេងៗដែលជាវត្ថុស័ក្ដិសិទ្ធិ ។ គ្នាគាត់ពីរបីនាក់រួមជាមួយគាត់ផង នាំគ្នាធ្វើដំណើរទៅតាមជ្រោះភ្នំទៅធ្វើថ្នាំ ទៅយកត្បូងហៅថាកែវមុនីទិព្វ និងព្រះពុទ្ធរូប ដែលកាលទេវតាច្បាំងគ្នាបានទុកឲ្យគាត់ ។ តាមរយៈវីដេអូ ឃើញគាត់កាយដីខ្សាច់

តាមជ្រលងភ្នំ ឃើញវត្ថុស័ក្តិសិទ្ធិទាំងនោះ ។ ក្នុងសម័យកុំព្យូទ័រនេះ មនុស្ស មិនល្ងង់ទេ វត្ថុទាំងនេះពិតជាស្តាយយកទៅកប់ ។ ពេលកប់ក្នុងខ្សាច់មិនថតទេ លុះកប់រួចពេលទៅកាយយកទើបថត ។ អ្នកជឿគាត់ចំពោះអ្នកដែលគ្មានការ ពិចារណាប៉ុណ្ណោះ ។ ព្រះពុទ្ធរូបតូចធំច្រើនគង់លើផ្កាឈូក ហើយមានស្នាម ខ្មៅមួយជុំត្រង់ចន្លោះចិញ្ចើម គឺជាសិល្បៈរចនាបថចិន ។ របស់ដែលមានលក់ នៅបរទេស មានថ្មរាងមូលតូច ដែលគេថាជាពងនាគ, ពូថៅទិព្វ, ដាវទិព្វ (ដាវ នេះគេឃើញលក់នៅប្រាសាទបន្ទាយស្រី និងនៅលើភ្នំគូលែន) ជាដើម ។ ការ លក់វត្ថុទាំងនេះ ជារបៀបធ្វើជំនួញដោយយកព្រះពុទ្ធសាសនាជាមធ្យោបាយ ។

តាមការទេសនារបស់គាត់តាមទូរស័ព្ទ គ្មានហេតុផលដែលគួរយកមកពិចារ ណាសោះឡើយ មានតែអួតខ្លួនគាត់ជាអ្នកមានបុណ្យរបូត តាំងខ្លួនជាព្រះពុទ្ធ ដោយប្រើពាក្យថាតថាគត ហើយត្មះតិះដៀលព្រះសង្ឃព្រះពុទ្ធសាសនាដែល បួសត្រឹមត្រូវតាមធម៌វិន័យព្រះពុទ្ធសាសនាថែមទៀត ។ គាត់តាំងបុរសម្នាក់នៅ សហរដ្ឋអាមេរិក ថាជាព្រះអរហន្ត សូម្បីព្រពន្ធគាត់ក៏ជាអរហន្តដែរ ។ ការធ្វើ បង្គន់១០០ហើយឃោសនា និងធ្វើព្រះវិហារបណ្តោយកន្លះគីឡូម៉ែត្រ (៥០០ ម៉ែត្រ) ។ ការធ្វើហួសពីសេចក្តីត្រូវការនេះ ជាការបំផ្លាញថវិកាខ្មែរ ជាភាពវង្វេង វង្វាយតាមការនឹកឃើញ ។

អដ្ឋង្គិកមគ្គ ប្រែថាមគ្គប្រកបដោយអង្គ៨ រួមមកបានដល់ទានសីលភាវនា ឬសីលសមាធិបញ្ញា ជាផ្លូវចេញចាកទុក្ខមានជាតិទុក្ខជាដើម មិននាំគ្នាសិក្សាឲ្យ យល់សេចក្តីហើយប្រតិបត្តិតាម ពេលដែលជួបព្រះពុទ្ធសាសនាមានគម្ពីរព្រះ ត្រៃបិដកជាគោល បែរជាមានមនុស្សមួយភាគតូចនាំគ្នាជឿអបិយ៍ជំនឿ ពុំមែន ជាធម៌ ជាវិន័យ ឃោសនាប្រាសចាកសេចក្តីពិត ។ គ្មានវត្ថុស័ក្តិសិទ្ធិណាជួយ មនុស្សសត្វឲ្យអស់ទុក្ខ ក្រៅពីប្រតិបត្តិតាមមគ្គប្រកបដោយអង្គ៨នេះឡើយ ។

❄ ❄

❄